**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៧ សរ

# សារាចរ

## ស្តីពី

## ការគ្រប់គ្រង និងការប្រើប្រាស់ត្រា នៅតាមក្រសួង-ស្ថាប័ន

កន្លងមក រាជរដ្ឋាភិបាល បានសង្កេតឃើញថា ក្រសួង-ស្ថាប័ន បានដំណើរការយ៉ាងសកម្ម ក្នុងការចូលរួមអនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល ដោយសំរេចបានលទ្ធផលជាផ្លែផ្កា គួរជាទីមោទនៈ ។ ប៉ុន្តែ រយៈពេលចុងក្រោយនេះ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៣ នាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣មក រាជរដ្ឋាភិបាល ក៏បានពិនិត្យឃើញថា ដំណើរការខាងលើ ពិសេសការប្រើប្រាស់ត្រារបស់ក្រសួង-ស្ថាប័នមួយចំនួន មានការរអាក់រអួល ដែលជះឥទ្ធិពលអវិជ្ជមាន ដល់យន្តការគ្រប់គ្រង និងចាត់ចែងការងាររដ្ឋបាលសាធារណៈប្រចាំថ្ងៃ បណ្តាលមកពីប្រធានស្ថាប័នមួយចំនួន បានយកតាមខ្លួននូវត្រារបស់ក្រសួង-ស្ថាប័ន ទៅជាមួយ ។

ដើម្បីពង្រឹង និងធានាបាននិរន្តរភាពការងាររដ្ឋបាលសាធារណៈ នៅតាមក្រសួង-ស្ថាប័ន ក៏ដូចជាការអនុវត្តតាមស្មារតី នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន រាជរដ្ឋាភិបាលសូមធ្វើការណែនាំ និងដាក់បញ្ជាដល់សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័ន ត្រូវប្រគល់ត្រាទៅឱ្យអគ្គនាយកដ្ឋានរដ្ឋបាល ឬ នាយកដ្ឋានរដ្ឋបាល សំរាប់គ្រប់គ្រង និងប្រើប្រាស់លើរាល់លិខិតបទដ្ឋាន និងលិខិតកិច្ចការរដ្ឋបាល ផ្សេងៗទៀត របស់ក្រសួង-ស្ថាប័ន ចាប់ពីថ្ងៃនេះតទៅ ។

ទទួលបានសារាចរនេះ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័ន ត្រូវអនុវត្តតាមខ្លឹមសារខាងលើ ឱ្យបានសំរេចលទ្ធផលជាវិជ្ជមាន ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ